ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** — **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌ — **នាមនាមប្រជារាស្ត្រខ្មែរ**

លេខ : ១២៥ — **តុលាការកំពូល**

ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤

សាលដីកា

លេខ : ៧៨

ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៥

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | ជីវ កេង | ចៅក្រម |
| ៤- លោក | ប្រាក់ គីមសាន | ចៅក្រម |
| ៥- លោក | ម៉ុង មុន្នីចរិយា | ចៅក្រម-របាយការណ៍ |

ក្រឡាបញ្ជី

លោក **ឈាង ទន្លា**

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ២៧ "ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ១២៥ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ពិរុទ្ធ*** : ចោរកម្ម (លួចសេវាទូរស័ព្ទចេញ-ចូលក្រៅប្រទេស) ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១-ជនជាប់ចោទឈ្មោះប៉ូលី ម៉ែន (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្វាយជាតិ ឃុំរាំងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃភូមិព្រែកទាល សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ មុខរបរចាងហ្វាងសាពតិមាន ប្រពន្ធឈ្មោះសុខ ខេមា មានកូន០៨នាក់ ឪពុកឈ្មោះប៉ូ ឯម "ស" ម្តាយឈ្មោះលី ឃុនលី "រ" ។

២-ជនជាប់ចោទឈ្មោះ PAUL ហៅ PAUL HELTON (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិអង់គ្លេស សាសនាគ្រិះស្ត មុខរបរប្រធានក្រុមហ៊ុន Online ។

-មានមេធាវី លោក សេង សុរីណា (តំណាងអង្គការ CRDP)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះចែម សង្វារ (ម្ចាស់បណ្តឹងសាទុក្ខ) តំណាងឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ភេទប្រុស មុខរបរអនុប្រធាននាយកដ្ឋានអធិការកិច្ច មានទីលំនៅសព្វថ្ងៃផ្លូវលេខ១៣ កែង១០២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

-មានមេធាវី លោក អ៊ា ដារ៉ា

-តាមលិខិតលេខ១៣១៧ បទច ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ (សូ ឃុន) បានបញ្ជាក់ថា : កន្លងមកបទល្មើសបង្កឡើងដោយជនល្មើសមួយក្រុមបានឃុបឃិតគ្នាតំឡើងប្រព័ន្ធ SDSL512 KbS ខុសច្បាប់ ដោយបញ្ចៀសស៊ីញ៉ា ហៅចេញចូលទៅអន្តរជាតិពុំឆ្លងកាត់លេខកូដរបស់ក្រសួងប្រៃសណីយ៍ឡើយ ។ បញ្ហានេះហើយដែលបង្កមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់ថវិកាជាតិ ។ តាមលទ្ធផលស្រាវជ្រាវបញ្ជាក់ថា ផ្ទះលេខ២៥៥ ផ្លូវលេខ៦៣ កែងលេខ២៤៥ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ដែលកំពុងប្រព្រឹត្តបទល្មើសបើកច្រកសេវាទូរស័ព្ទចេញចូលអន្តរជាតិខុសច្បាប់ ។

-បានឃើញដីកាសំរេចលេខ៩៣២៧តព្រ "ញ" ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-លើកលែងចោទប្រកាន់លើឈ្មោះប៉ូលី ម៉ែន ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ ឈ្មោះ PAUL ហៅ PAUL HILTON ព្រមទាំងគូកនពីបទចោរកម្ម (លួចសេវាទូរស័ព្ទចេញចូលក្រៅប្រទេស) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ ហើយដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលជាស្ថាពរ ។

២-បង្គាប់អោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលមានលោកចែម សង្វារ ជាតំណាង ប្រគល់សំភារៈមួយចំនួន :

1-CISCO 2611 1 UNIT
2-CATALYST 2950 1 UNIT
3-SDSL Networt Extender 2000 1 UNIT
4-Server IBII 1 UNIT
5-UPS LEONICS 1 UNIT
6-Power (Automatic Vohage 15 (VA)) 1 UNIT
7-Tlouitor (Five Star) 1 UNIT
8-Telephone Set DT700 1 UNIT
9-Computer 3 Unit Printer HP Cacerject 1000 Series 1Unit
10-Captop (Computer Sony) 1Unit
11-Computer 17 Unit
12-Power (Automatic Vohage 15 (VA)) 1Uint
13-Computer 10Unit

14-Catalyst 2950 1 Unit
15-Power (Automatic Vohég 15 KVA 1Unit
16-តុចំនួន ០៥
17-កៅអី ចំនួន ១៦

ដែលបានដកហូតតាមកំណត់ហេតុឆែកឆេរលំនៅដ្ឋាន ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ អោយទៅអង្គការកម្មវិធីស្ពារ និងអភិវឌ្ឍន៍កម្ពុជាដែលមានលោក បែនសុន សម័យ ជាតំណាង ប្រើប្រាស់ជាកម្មសិទ្ធិវិញ ។

៣-បង្គាប់អោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលមានលោកចែម សង្វារ ជាតំណាងប្រគល់ប្រាក់ចំនួន២៧២៧៨៛ អោយទៅអង្គការកម្មវិធីស្ពារ និង អភិវឌ្ឍន៍កម្ពុជា ដែលមានលោកបែនសុន សម័យ ជាតំណាងវិញ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់លោកអ៊ា ដារ៉ា មេធាវីតំណាងឱ្យក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ , បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ របស់លោកចែម សង្វារ តំណាងអោយដើមបណ្តឹងរដ្ឋប្បវេណី ,បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះប៉ូលី ម៉ែន និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃ ទី២៩ ខែធ្នូ ឆ្នាំ២០០៣ របស់លោកព្រះរាជអាជ្ញារង អមតុលាការក្រុងភ្នំពេញ ប្តឹងមិនសុខចិត្តពីដីកាសំរេចលេខ៩៣២៧តព្រ "ញ" ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣ របស់ចៅក្រម ស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើដីកាសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា : ផ្អែកតាមលិខិតណែនាំរបស់ឯកឧត្តមប្រធានតុលាការកំពូល ឃើញថា អំពើរបស់លោក PAULHILTON&POLIMEN មិនមែនជាបទល្មើសទេ ដូចនេះការលើកលែងការចោទប្រកាន់គឺជាការត្រឹមត្រូវ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៧"ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ របស់លោកអ៊ា ដារ៉ា មេធាវីតំណាងឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ,បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ របស់លោកចែម សង្វារ តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ,បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ ឈ្មោះប៉ូលី ម៉ែន និង បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញារង អមតុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តំកល់ដីកាសំរេចលើកលែងចោទប្រកាន់លេខ៩៣២៧ត.ព្រ"ញ" ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៤ចំពោះមុខលោកសេង ស៊ីណា លោកចែម សង្វារ , លោកអ៊ា ដារ៉ា កំបាំងមុខលោកប៉ូលី មែន Paul Hilton និង ប្រកាសជាសាធារណៈ

នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ ចំពោះមុខលោកសេង សុវីណា កំបាំងមុខលោកចែម សង្វារ ,លោក អ៊ាដាក់ ,លោក ប៉ូលី ម៉ែន Paul Hilton ,បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១២០ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះចែម សង្វារ និង បណ្តឹងសាទុក្ខលេខ១០៦ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះប៉ូលី ម៉ែន ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ២៧"ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៤ របស់លោកចែម សង្វារ(ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ របស់លោកប៉ូលី ម៉ែន (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ របស់លោក មេធាវីសេង សុវីណា (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៥ របស់លោកប៉ូលី ម៉ែន (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

+សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះត្រឹមត្រូវហើយ

+តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៧ "ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះប៉ូលី ម៉ែន (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ខ្លួនមិនសុខចិត្តនឹងការដែលតុលាការសម្រេចប្រគល់ទ្រព្យរឹបអូសទៅលោកប៉ែន ស៊ុនសម័យ ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាការពាររបស់ដើមបណ្តឹងរដ្ឋប្បវេណីតំណាងដោយចែម សង្វារ នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសេង សុវីណា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះប៉ុល ហ៊ីលតុន ជាអ្នកតំណាងអង្គការ CRDP (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ការគ្រប់គ្រងសេវាកម្ម Internet ស្ថិតក្រោមសិទ្ធិរបស់ក្រុមហ៊ុន Gonetel online ដែលបានទទួលអាជ្ញាប័ណ្ណពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមរយៈការផ្ទេរអាជីវកម្មពីក្រុមហ៊ុន Tel star International Limited CAN ដែល បានចុះកិច្ចសន្យាព្រមព្រៀងជាមួយភាគីរដ្ឋ រឺតំណាងអង្គការកម្មវិធីស្ពារ និង

អភិវឌ្ឍន៍កម្ពុជាគ្រាន់តែជាអតិថិជនរបស់ក្រុមហ៊ុន Gogetel ដែលបានជាវសេវាកម្មទៅប្រើប្រាស់ប៉ុណ្ណោះ ។

ប្រព័ន្ធទូរស័ព្ទពុំមែនជាចលនទ្រព្យ មានរូបរាងអាចចាប់កាន់ ឬ ផ្លាស់ទីកន្លែងបានដែលជាធាតុផ្សំនៃបទល្មើសចោរកម្មតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ បានឡើយ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ នៅពេលជំនុំជំរះថា: គ្មានយោបល់អ្វីបន្ថែមទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់តំណាងដើមបណ្តឹងរដ្ឋប្បវេណី ,ចម្លើយឈ្មោះប៉ូលី ម៉ែន និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១២០ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤របស់ឈ្មោះចែម សង្ហា តំណាងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និង បណ្តឹងសាទុក្ខលេខ១០៦ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះប៉ូលី ម៉ែន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពសាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក៏ដូចជាតុលាការក្រុងភ្នំពេញដែរ ដែលបានសម្រេចមិនចោទប្រកាន់លើលោក ប៉ូលី ម៉ែន និង លោក ប៉ុល ហ៊ីលតុន ជាអ្នកតំណាងអង្គការកម្មវិធីស្តារ និង អភិវឌ្ឍន៍កម្ពុជា ពីបទចោរកម្មលើប្រព័ន្ធទូរស័ព្ទក្រៅប្រទេស នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៣ នោះ ជាការត្រឹមត្រូវហើយ ដោយហេតុថា :

+ការគ្រប់គ្រងសេវាកម្ម Internet ស្ថិតក្រោមសិទ្ធិរបស់ក្រុមហ៊ុន Gogete (ONLINE) ដែល បានទទួលអាជ្ញាប័ណ្ណពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈការផ្ទេរអាជីវកម្មពីក្រុមហ៊ុន Telstra International Limited CAN ដែលបានចុះកិច្ចព្រមព្រៀងជាមួយភាគីរដ្ឋ រីឯអ្នកតំណាងអង្គការកម្មវិធីស្តារ និង អភិវឌ្ឍន៍កម្ពុជា គ្រាន់តែជាអតិថិជនរបស់ក្រុមហ៊ុន Gogetel ដែលបានជាវសេវាកម្មទៅប្រើប្រាស់ប៉ុណ្ណោះ ។

+ប្រព័ន្ធទូរស័ព្ទពុំមែនជាចលនទ្រព្យមានរូបរាង អាចចាប់កាន់ ឬផ្លាស់ទីកន្លែងបានដែលជាធាតុផ្សំនៃបទល្មើសចោរកម្ម តាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ឡើយ ។

-យល់ឃើញថា ការដែលលោកប៉ូលី ម៉ែន បានលើកឡើងនៅក្នុងសារណារបស់ខ្លួន ក៏ដូចជានៅពេលសវនាការនេះដែរ ដែលថា ខ្លួនមិនសុខចិត្តនឹងការដែលតុលាការសម្រេចប្រគល់ទ្រព្យរឹបអូស ឱ្យទៅលោកប៉ែនស៊ុន សម័យ នោះ ជាការភ័ន្តច្រឡំ ព្រោះថា បុគ្គលដែលតុលាការអង្គសេចក្តីប្រគល់ទ្រព្យដែលរឹបអូសឱ្យនោះ គឺអង្គការកម្មវិធីស្តារ និង អភិវឌ្ឍន៍កម្ពុជា ហើយគ្រាន់តែដាក់លោកប៉ែនស៊ុន សម័យ ជាតំណាងប៉ុណ្ណោះ ។

-យល់ឃើញថា ការដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនៅក្នុងសារណារបស់លោកថា ជនជាប់ចោទបានឃុបឃិតគ្នាលួចបណ្តាញទូរស័ព្ទធ្វើឱ្យប៉ះពាល់ដល់បណ្តាញទូរស័ព្ទក្រៅប្រទេស និង សុំទាមទារសំភារៈដែលរឹបអូសបានអោយក្រសួងគ្រប់គ្រងថែរក្សានោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះតាមគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ បើច្បាប់ពុំបានចែងថា អំពើណាមួយជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសទេ តុលាការព្រហ្មទណ្ឌពុំមានសមត្ថកិច្ចសំរេចតាមសំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណីបានទេ ។

-យល់ឃើញថា តំណាងដើមបណ្តឹងបានសុំពន្យាពេលសវនាការទៅថ្ងៃក្រោយ តុលាការកំពូលពុំអាចអនុញ្ញាតបានទេ ពីព្រោះសាមីខ្លួនពុំមានមូលហេតុ និង ពុំមានភស្តុតាងត្រឹមត្រូវ ។ ប៉ុន្តែដោយសាមីខ្លួនបានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ តុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា តំណាងអង្គការ CRDP ពុំបានមកចូលរួមនាសវនាការនេះទេ ប៉ុន្តែមេធាវីបានមកចូលរួមហើយ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២៧"ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលសម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

**ហេតុដូចន្នេះ**

***វិនិច្ឆ័យសេចក្តីចំពោះមុខឈ្មោះប៉ូលី ម៉ែន កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី***

***និង តំណាងអង្គការ CRDP ប៉ុន្តែចាត់ទុកជា ចំពោះមុខ :***

**១-ទទួលបណ្តឹងសាទុក្ខលេខ១២០ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះចែម សង្វា តំណាងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និង បណ្តឹងសាទុក្ខលេខ១០៦ ចុះថ្ងៃទី១៦ ខែកញ្ញា**

ឆ្នាំ២០០៤ របស់ឈ្មោះប៉ូលី ម៉ែន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៧ "ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៥ ។ ៚